# បន្ទប់ព័ត៌មានស្តីពីស្ថានភាពបោះឆ្នោតឆ្នាំ២០១៣

## (បន្ទប់ស្ថានភាព)




## ១. គោលបំណង ៖ ផ្តល់ដំណឹងរួមគ្នា អន្តរាគមន៍រួមគ្នា និងវាយតម្លៃរួមគ្នា

- ប្រមូលផ្តុំបណ្តាអង្គការសង្គមស៊ីវិល[1] អ្នកជំនាញ និងភាគីពាក់ព័ន្ធនឹងការបោះឆ្នោតដទៃទៀត រួមគ្នា ដើម្បីជា ធនធានកម្រិតអតិបរមា និង ផ្តល់នូវវេទិកាសហការគ្នាមួយ សម្រាប់ការវាយតម្លៃរួមគ្នា ផ្ទៀងផ្ទាត់រួមគ្នាលើលទ្ធផលបោះឆ្នោត អន្តរាគមន៍ និងផ្តល់ជាអនុសាសន៍ អំឡុងពេលបោះឆ្នោត។ ជំនួបនេះ រាប់បញ្ចូល អំឡុងពេលមុនថ្ងៃបោះឆ្នោត ព្រឹត្តិការណ៍ថ្ងៃបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងមូលបញ្ហាក្រោយថ្ងៃបោះឆ្នោតភ្លាមៗដូចជា បណ្តឹងបោះឆ្នោត ការបោះឆ្នោតឡើងវិញ និងការផ្ទេរអំណាច។

[1] រួមមាន COMFREL, NICFEC, ADHOC, LICADHO (tbc), CDP, CHRAC, CLEC, CPWP, Silaka, KYA, YRDP, DHRAC, KYSD, YCC (tbc), ICSO, CPWP, GAD/C, CISA, PDP- Center, NGO Forum, Star Kampuchea, API, WMC (tbc), CCHR,CCIM/VOD, DPA, LWD, CDPO (tbc), CHRAC, TIC, My Village Organization (MVI), KID, VBNK, HR Vigilance, LICADHO (tbc) និងក្រុមការងារអន្តរជាតិផ្សេងទៀត។.

- វេទិការួមគ្នានេះ គឺត្រូវបានរៀបចំឡើង ដើម្បីចែកផ្សាយដំណឹងភ្លាមៗទាក់ទងនឹងថ្ងៃបោះឆ្នោត ប្រមូលបានមកពី អ្នកសង្កេតការណ៍របស់អង្គការសង្គមស៊ីវិល ក្រុមការងារពាក់ព័ន្ធ សហគមន៍ជាតិ និងអន្តរជាតិ ដែលចាប់អារម្មណ៍នឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងប្រទេសកម្ពុជា ខណៈដែលកិច្ចអន្តរាគមន៍ត្រៀមចាំទប់ទល់ជាមុន នឹងធ្វើឱ្យប្រសើរឡើង និងឆ្លើយតបយ៉ាងរហ័សចំពោះវិបត្តិដែលទាក់ទងនឹងបរិយាកាសក្នុងថ្ងៃបោះឆ្នោត។

**២. ពេលណា** ? ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣

**៣. បន្ទប់ស្ថានភាពនៅកន្លែងណា** ? តង់សំណាក់ទំហំ ៨០ម៉ែត្រ (អាចផ្ទុកអ្នកចូលរួមបានប្រមាណ ៨០នាក់) នឹងរៀបចំនៅខាងក្រៅការិយាល័យ ខុមហ្វ្រែល ដោយមានបំពាក់សម្ភារៈផាលសុខភាព សម្រាប់អំឡុងពេលពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣។

**៤. អ្នកសង្កេតការណ៍ក្នុងថ្ងៃបោះឆ្នោត** ៖ រាប់បញ្ចូលអ្នកសង្កេតការណ៍ខុមហ្វ្រែល ចំនួន ១០០០០ (មួយម៉ឺន)នាក់ (រាប់បញ្ចូលបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត) អង្គការ ជ្រាក ចំនួន ២០០០ (ពីរពាន់)នាក់ សមាគមយុវជនខ្មែរ ចំនួន ៧០០ (ប្រាំពីររយ)នាក់ អង្គការតម្លាភាពអន្តរជាតិកម្ពុជា/សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម ចំនួន ៩០០ (ប្រាំបួនរយ) នាក់ គណៈកម្មាធិការ និកហ្វិច ចំនួន ៣០០០ (បីពាន់)នាក់។

**ខុមហ្វ្រែល** និង **បន្ទប់ព័ត៌មានអំពីស្ថានភាពបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣** សូមអំពាវនាវដល់ ម្ចាស់ឆ្នោត និងពលរដ្ឋចូលរួមសង្កេតការណ៍ រាយការណ៍ បញ្ជូនរូបភាពទាក់ទងនឹងការបោះឆ្នោត ភាពមិនប្រក្រតីក្នុងពេលបោះឆ្នោត ឬបណ្ដឹងផ្ទាល់មាត់ មកកាន់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ ខុមហ្វ្រែល រួមមាន គេហទំព័រ បណ្ដាញព័ត៌មានសង្គម និងទូរស័ព្ទបន្ទាន់៖ 010/015-802-777 ឬ 012-43-34-37 ឬ 016-54-43-98 និង

- COMFREL: www.comfrel.org; www.facebook.com/comfrel.org ; or www.youtube.com/user/comfrel; and www.ustream.tv/channel/comfrel
- CVV: www.cambodianvotervoice.org; www.facebook.com/cvv.org; www.youtube.com/user/CambodianVoterVoice; and twitter.com/CamVoterVoice

## ៥. តារាងកម្មវិធីនៃការចេញផ្សាយដំណឹង ប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍

a. **<u>ព័ត៌មាន/ដំណឹងបោះឆ្នោតជាញឹកញាប់</u>** នឹងត្រូវបានផ្សព្វផ្សាយតាមរយៈ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយអនឡាញ ៖ សម្លេងម្ចាស់ឆ្នោតកម្ពុជា (គេហទំព័រខុមប្រៀល គេហទំព័រសម្លេងម្ចាស់ឆ្នោតកម្ពុជា កម្មវិធីប្រើប្រាស់លើទូរស័ព្ទ [mobile app] ទ្វីតត័រ [Twitter] ហ្វេសប៊ុក [Facebook] វីដេអូ [ Video Ustream]) វិទ្យុសម្លេងប្រជាធិបតេយ្យ [VOD/CCIM] មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា [WMC] វិទ្យុFM 102MHz កម្មវិធីផ្សព្វផ្សាយរបស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា [CCHR] មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ [CLEC] និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។

b. **<u>បទវិភាគស្ថានការណ៍បោះឆ្នោតសង្ខេបប្រចាំថ្ងៃ</u>** នឹងត្រូវបានរៀបចំឡើងនៅក្នុង តង់សំណាក់នៃបន្ទប់ស្ថានភាព រៀងរាល់ម៉ោង ១០ព្រឹក និងម៉ោង ៣:៣០នាទីរសៀល ដើម្បីបញ្ជាក់ពីបរិយាកាសនយោបាយ នីតិវិធី ការព្រឹត្តិទៅ និងសំណើសម្រាប់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) / អាជ្ញាធរដើម្បីអន្តរាគមន៍ (បទវិភាគនេះមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់បន្ទប់ស្ថានភាពឡើយ)។ អ្នកសម្របសម្រួល រួមមាន លោក គល់ បញ្ញា ឬលោក យង់ គិមអេង។ វាគ្មិនខាងក្រោម នឹងបញ្ជាក់ពីការចូលរួម៖

- **ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ ៖ ក្រោយយុទ្ធនាការឃោសនាបោះឆ្នោត**
    - ម៉ោង ១០ព្រឹក ៖ វាគ្មិន លោកបណ្ឌិត **ឡៅ ម៉ុងហៃ** លោកបណ្ឌិត **កែម ឡី** លោក **អ៊ូ វិរៈ** (ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា CCHR) លោក **ហ៊ឹម យន់** (សមាគមយុវជនខ្មែរ KYA)
- **ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣ ៖ ថ្ងៃស**
    - ម៉ោង ១០ព្រឹក ៖ វាគ្មិន លោកស្រី **ជា វណ្ណាត** លោកមេធាវី **សុក សំអឿន** (នាយក ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា CDP) លោក **យ៉េង វិរៈ** (ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ CLEC) និងលោកបណ្ឌិត **ហង្ស ពុទ្ធា** (នាយកប្រតិបត្តិ គណៈកម្មាធិការ និកហ្វិច NICFEC)
    - ម៉ោង ៣:៣០នាទី រសៀល ៖ វាគ្មិន លោកស្រី **ធីតា ឃឹះ** (នាយិកា អង្គការសីលការ CPWP/Silaka) លោក **អ៊ូ វិរៈ** (ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស

កម្ពុជា CCHR) លោក **ជាង សុខា** នាយកប្រតិបត្តិ អង្គការកម្មវិធីអភិវឌ្ឍធនធានយុវជន YRDP)

- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ៖ ថ្ងៃបោះឆ្នោត
  - ម៉ោង ១០ព្រឹក ៖ វាគ្មិន លោក **នី ចរិយា** (ប្រធានអង្កេត សមាគមអាដហុក ADHOC) លោក **យ៉េង វីរៈ** លោក **ជាង សុខា** លោក **ខិម សំអាត** ប្រធានអង្កេត អង្គការលីកាដូ LICADHO)
  - ម៉ោង ៣:៣០នាទី រសៀល ៖ វាគ្មិន លោកមេធាវី **សុក សំអឿន** លោកបណ្ឌិត **ឡៅ ម៉ុងហៃ** លោក **ប៉ាង ខួនឡៀង** នាយក មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM)
- ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ ៖ វិភាគលទ្ធផលបោះឆ្នោត និងក្រោយការបោះឆ្នោត/ដំណោះស្រាយបណ្តឹង
  - ម៉ោង ៣:៣០នាទី រសៀល ៖ វាគ្មិន លោក **អ៊ូ វីរៈ** លោកបណ្ឌិត **កែម ឡី** លោកមេធាវី **សុក សំអឿន** លោកបណ្ឌិត **ឡៅ ម៉ុងហៃ** លោក **ហ៊ីម យ៉ន់** លោកបណ្ឌិត **សុក ទូច** លោក **នី ចរិយា**

c. <u>សន្និសីទសារព័ត៌មាន</u>

- របាយការណ៍បឋមស្តីពី បរិយាកាសមុនថ្ងៃបោះឆ្នោត នឹងត្រូវបានផលិត ហើយសន្និសីទសារព័ត៌មានមួយ នឹងត្រូវបានធ្វើឡើង នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ នាវេលាម៉ោង ៣រសៀល នៅ តង់សំណាក់នៃបន្ទប់ស្ថានភាព។ (គណៈអធិបតី ៖ លោក **ធន សារ៉ាយ** លោក **គល់ បញ្ញា** លោក **សុក សំអឿន** លោកស្រី **ធីតា ឃឹះ** លោកបណ្ឌិត **ហង្ស ពុទ្ធា** លោក **ហ៊ីម យ៉ន់**)
- ការរកឃើញបឋមស្តីពី ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត នឹងត្រូវបានបង្ហាញនៅក្នុង សន្និសីទសារព័ត៌មាន នៅ តង់សំណាក់នៃបន្ទប់ស្ថានភាព។
  - ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ៥ល្ងាច ៖ វាគ្មិន លោក **ធន សារ៉ាយ** លោក **សុក សំអឿន** លោកស្រី **ធីតា ឃឹះ** លោកបណ្ឌិត **ហង្ស ពុទ្ធា**

លោកស្រីបណ្ឌិត **ពុទ ឈីទកេក** លោក **ម៉ាក ចំរើន** លោក **គល់ បញ្ញា** លោក **គាន ពន្លក**

○ **ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១០:៣០នាទី ព្រឹក** ៖ វាគ្មិន លោក **ធន សារ៉ាយ** លោក **គល់ បញ្ញា** លោក **សុក សំអឿន** លោកបណ្ឌិត **ហាង ពុទ្ធា** កញ្ញា **គង់ រ៉ាវឌន** លោក **ហ៊ឹម យ៉ន់** លោក **គាន ពន្លក**

- សន្និសីទសារព័ត៌មានវិសាមញ្ញ នៅក្នុងកាលទេសៈប្លែកពីធម្មតា ដូចជា វិបត្តិបោះឆ្នោត អំពើហិង្សាបោះឆ្នោត ភាពមិនប្រក្រតី/ការលួចបន្លំធ្ងន់ធ្ងរ និងអំពើហិង្សាដែលអាចនឹងធ្វើឡើងនៅ តង់សំណាក់ នៃបន្ទប់ស្ថានភាព ប្រសិនបើចាំបាច់។

d. **<u>កិច្ចពិភាក្សាតុមូល</u>**

សេចក្តីថ្លែងការណ៍វាយតម្លៃចុងក្រោយមួយ ជាមួយនឹងរបាយការណ៍សង្ខេបមួយ ស្តីពីដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកសភា នឹងត្រូវបានផលិតឡើង ហើយកិច្ចពិភាក្សាតុមូលមួយនឹង ត្រូវបានរៀបចំឡើង នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ៨:៣០នាទី ព្រឹក នៅ សណ្ឋាគារ អ៊ីមផារៀល ឬសណ្ឋាគារ សាន់វ៉េ។